# អនុត្តរិយៈ

## និង

# សិក្សាតាមព្រះ




រៀបរៀងដោយ ខ្ញុំព្រះករុណា

ស៊ិន អក្ខរា


សម្រាប់ជាធម្មទាន

# បុព្វកថា

( បិដកលេខ ៥២ ទំព័រ ៣២២-៣២៣ )

ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានឈ្មោះថា **អជាតៈ** ឈ្មោះថា **អភូតៈ** ឈ្មោះថា **អកតៈ** ឈ្មោះថា **អសង្ខតៈ** មានប្រាកដ ម្នាលភិក្ខុ-ទាំងឡាយប្រសិនណាបើព្រះនិព្វាននោះឈ្មោះថា **អជាតៈ** ឈ្មោះថា **អភូតៈ** ឈ្មោះថា **អកតៈ** ឈ្មោះថា **អសង្ខតៈ** មិនមានទេ ការរលាស់ចេញនូវកិលេស ដែលនាំឱ្យកើតមហាភូតរូប ដែលប្រាកដនូវហេតុ ដែលធ្វើនូវបច្ច័យដែលតាក់តែង ក្នុងលោកនេះក៏មិនប្រាកដ ។

ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វាន ឈ្មោះថា **អជាតៈ** ឈ្មោះថា **អភូតៈ** ឈ្មោះថា **អកតៈ**

ឈ្មោះថា **អសង្ខតៈ** រមែងមានប្រាកដ ព្រោះហេតុណា ហេតុនោះ ការរលាស់ចេញនូវកិលេ-ស ដែលនាំឱ្យកើតមហាភូតរូបដ៏ប្រាកដ នូវហេតុដែលគួរធ្វើ នូវបច្ច័យជាទីតាក់តែង ក៏រមែងប្រាកដ ( នេះជាព្រះពុទ្ធដីកា ) ។

ការកើត ចាស់ ឈឺ ស្លាប់ គឺជារឿងមួយដែលអន្ទបុថុជ្ជន មិនងាយនឹងគេចវេសបាន ពីព្រោះជនល្ងិតល្ងង់មានអវិជ្ជាជាធម៌ឯក មិនមានធម៌ដទៃក្រៃលែងជាង ។ សូមឱ្យបរិស័ទបានរួចចាកវដ្តសង្សារនិងបាននូវនិព្វានសម្បត្តិគ្រប់ៗគ្នា សូមអនុមោទនា ។

**វត្តហ្លួង ថ្ងៃសុក្រ ១៥ កើត ខែពិសាខ ឆ្នាំមមាញ់ បញ្ចស័ក**

**ពុទ្ធសករាជ ២៥៥៦ ពីខ្ញុំ. ស៊ិន អក្ខរា**

# ១-ទស្សនានុត្តរិយៈ

( បិដកលេខ ៤៦ ទំព័រ ១០ )

ពាក្យថា ទស្សនានុត្តរិយៈ គឺ មានន័យថា ការឃើញដ៏ប្រសើរ។ នៅក្នុងគម្ពីរ បដិសម្ភិទា -មគ្គ មានសម្តែង និង អដ្ឋកថាផងដែរ ដែល ព្រះអង្គទ្រង់ត្រាស់សម្តែងថា ៖

ម្នាលភិក្ខុទាំងឡាយ ទស្សនានុត្តរិយៈ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ នៅក្នុងលោកនេះ រមែងទៅដើម្បីនឹងមើលដំរី កែវខ្លះ សេះកែវខ្លះ កែវមណីខ្លះ របស់ធំខ្លះ របស់តូចខ្លះ ឬ សមណព្រាហ្មណ៍អ្នកយល់

ខុសខ្លះ បដិបត្តិខុសខ្លះ ម្នាលភិក្ខុទាំងឡាយ ទស្សនៈមាន តថាគតមិនពោលថាមិនមានទេ ម្នាលភិក្ខុទាំងឡាយ ដោយសេចក្តីថាទស្សនៈនេះនោះ ជាទស្សនៈដ៏អាក្រក់ ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនរបស់ព្រះអរិយៈ មិនប្រកដោយប្រយោជន៍ មិនប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីការរលត់ ដើម្បីសេចក្តីស្ងប់ ដើម្បីសេចក្តីដឹងដ៏ក្រៃលែង ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលណាមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំង

មាំ មានសទ្ធាមិនកម្រើក មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង រមែងទៅដើម្បីឃើញព្រះតថាគត ឬសាវកតថាគត ម្នាលភិក្ខុទាំងឡាយ ការឃើញនេះ ប្រសើរជាងការឃើញទាំងឡាយ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីឈានកន្លងនូវសេចក្តីសោកខ្សឹកខ្សួល ដើម្បីសេចក្តីរម្លត់បង់នូវទុក្ខ និងទោមនស្ស ដើម្បីសម្រេចញេយ្យធម៌ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ ប្រការដែលអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំង

មាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង បានឃើញព្រះតថាគត ឬ សាវករបស់ព្រះតថាគតទាំងឡាយ តថាគតហៅថា ទស្សនានុត្តរិយៈ ។

ន័យព្រះធម៌ខាងលើនេះ គឺ ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់បានបញ្ជាក់ឱ្យបរិស័ទគ្រប់គ្នាបានយល់ កុំឱ្យមានវិចិកិច្ឆានឹងទស្សនៈអវិជ្ជាទៀតនោះឯង ។

# ២-សវនានុត្តរិយៈ

( បិដកលេខ ៥៦ ទំព័រ ១០ )

ពាក្យថា សវនានុត្តរិយៈ គឺមានន័យថា ការស្តាប់ដ៏ប្រសើរ ។

នៅក្នុងបដិសម្ភិទាមគ្គ អដ្ឋកថា បាន សម្តែងថា ៖

ម្នាលភិក្ខុទាំងឡាយ តើសវនានុត្តរិយៈ នោះដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ បុគ្គល ខ្លះក្នុងលោកនេះរមែងទៅដើម្បីស្តាប់សំឡេង ស្គរខ្លះ សំឡេងពិណខ្លះ សំឡេងភ្លេងខ្លះ ឬ សំឡេងខ្លាំងៗខ្លះ តិចៗខ្លះ រមែងទៅដើម្បី

ស្តាប់ធម៌របស់សមណព្រាហ្មណ៍អ្នកយល់ខុសខ្លះ អ្នកបដិបត្តិខ្លះ ។

ម្នាលភិក្ខុទាំងឡាយ ការស្តាប់នេះមានតថាគតមិនបានពោលថា មិនមានទេ តែថាការស្តាប់នេះ ជាការស្តាប់ដ៏អាក្រក់ ។ល។ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលណាអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនកម្រើក មានសេចក្តីជ្រះថ្លាដ៏ប្រសើរ រមែងទៅដើម្បីស្តាប់តថាគត ឬសាវករបស់តថាគត ។

ម្នាលភិក្ខុទាំងឡាយ ការស្តាប់នេះប្រសើរជាងការស្តាប់ទាំងឡាយ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។ល។ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ សវនានុត្តរិយៈ គឺ មានន័យយ៉ាងឯង ។

ជាការពិតណាស់ ការស្តាប់តូរ្យតន្ត្រី ការប្រគំភ្លេងទាំងឡាយគ្រប់ម៉ូតគ្រប់ម៉ាក មានភ្លេងសម័យ មានភ្លេងបុរាណ មានចម្រៀងសម័យ មានចម្រៀងបុរាណជាដើម យើងស្តាប់វានៅពេលណា មានតែការចម្រើននូវ

អកុសលធម៌តែប៉ុណ្ណោះ តែប្រព្រឹត្តទៅដើម្បីកុសលធម៌គឺមិនមានសោះឡើយ ។ អ្នកស្តាប់ចម្រៀងខ្លះអាចនឹងស្រក់ទឹកភ្នែក ព្រោះតែការស្តាប់ចម្រៀង ព្រោះគិតអត្ថន័យបទចម្រៀងនោះ គឺ វាដូចជារឿងរបស់ខ្លួនឯងពេក ដូច្នេះបានជាទប់នូវទឹកភ្នែកមិនបាន ។ តាមពិតបទចម្រៀង គឺ នៅជាបទចម្រៀងដ៏ដែល មិនដែលមានបទចម្រៀងណា ដែលធ្វើឱ្យអ្នកយំក្រៅតែពីអ្នកខ្លួនឯង ធ្វើឱ្យខ្លួនឯងយំនោះឡើយ ។

ឥឡូវ យើងនឹងសិក្សាពីសំឡេងព្រះធម៌

វិញម្តង មានអ្នកខ្លះស្តាប់សំឡេងព្រះធម៌ ក៏ស្រក់ទឹកភ្នែកបានដូចគ្នាដែរ តែស្រក់ទឹកភ្នែកនេះមិនមែនស្រក់ទឹកភ្នែកព្រោះដូចរឿងរបស់ខ្លួនឯងនោះទេ តែស្រក់ព្រោះតែមានសេចក្តីតក់ស្លុត ចំពោះជីវិតរបស់សត្វលោកទៅវិញទេ តក់ស្លុតនោះគឺដូចជា សត្វទាំងឡាយទាំងពួងមិនទៀង ជាទុក្ខ ជាអនត្តា រហូតដល់មានការពិចារណាពីខ្លួនឯងក៏ស្ថិតនៅក្នុងសាមញ្ញលក្ខណៈដូចសត្វដទៃទៀតដែរ ។

សំឡេងព្រះធម៌ ដែលពុទ្ធបរិស័ទបាននឹងកំពុងតែស្តាប់ឬបានអាន គឺ ជាសំឡេង

ដែលកំពុងតែចង្អុល បង្ហាញប្រាប់ពីផ្លូវដ៏ល្អ បរិសុទ្ធដល់យើងគ្រប់គ្នា គឺ ជាផ្លូវដែលប្រកប ដោយអង្គ ៨ ប្រការ ។ អ្នកបានស្តាប់សំឡេង ព្រះធម៌គឺប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធ និង ដើម្បីបានចាក់ធ្លុះនូវព្រះនិព្វានផងដែរ ។

# ៣-លាភានុត្តរិយៈ

( បិដកលេខ ៨៦ ទំព័រ ១០ )

ពាក្យថា លាភានុត្តរិយៈ គឺ មានន័យថា ការបានលាភដ៏ប្រសើរ ។

នៅក្នុងអដ្ឋកថា បដិសម្ភិទាមគ្គសម្តែងថា ៖ ម្នាលភិក្ខុទាំងឡាយ តើលាភានុត្តរិយៈ មានន័យដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រមែងបានបុត្រខ្លះ ភរិយាខ្លះ ទ្រព្យខ្លះ ឬ លាភច្រើនខ្លះ តិចខ្លះ ឬ បានសទ្ធាក្នុងសមណព្រាហ្មណ៍អ្នកយល់ខុស អ្នកបដិបត្តិខុស ។

ម្នាលភិក្ខុទាំងឡាយ លាភគឺការបាននេះ មាន តថាគតមិនបានពោលថា មិនមានទេ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីថា លាភ គឺ ការបាននេះជាលាភអាក្រក់ ។ល។ មិនប្រព្រឹត្ត ទៅដើម្បីព្រះនិព្វានឡើយ ។

ម្នាលភិក្ខុទាំងឡាយ ចំណោកបុគ្គលណា ជាអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់ តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តី ជ្រះថ្លាដ៏ក្រៃលែង រមែងបាននូវសទ្ធាក្នុងព្រះ តថាគត ឬ សាវករបស់ព្រះតថាគត ។

ម្នាលភិក្ខុទាំងឡាយ លាភ គឺការបាន

នេះជាលាភដ៏ប្រសើរ ជាងលាភទាំងឡាយ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។បេ។ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ ការដែលបុគ្គលអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង រមែងបានសទ្ធាក្នុងព្រះតថាគត ឬសាវករបស់ព្រះតថាគតនេះ តថាគតហៅថា លាភានុត្តរិយៈ យ៉ាងនេះឯង ។

លាភ នៅក្នុងទីនេះគឺសំដៅទៅលើការ

បាននូវ សទ្ធា ចំពោះព្រះសម្មាសម្ពុទ្ធ ឬ ព្រះអរហន្តសាវកទាំងឡាយ គឺ មានន័យថា ជឿទៅលើគុណព្រះដ៏មានព្រះភាគ និង ព្រះសាវកទាំងឡាយផងដែរ ។

បើពោលពីជំនឿនៅក្នុងសម័យបច្ចុប្បន្ននេះវិញ គឺមានសភាពមិនល្អបរិសុទ្ធទាំងស្រុងនោះទេ បរិស័ទខ្លះ អ្នកបួសខ្លះ ក៏នៅតែមិនទាន់យល់ស៊ីជម្រៅដ៏ដែល ។ ខ្លះជឿគុណព្រះពុទ្ធមែន តែបែរជានាំគ្នាទៅបន់ស្រន់ឱ្យព្រះពុទ្ធជួយយ៉ាងនេះមួយ ជួយយ៉ាងនោះមួយដោយមិនព្រមកែប្រែនូវជំនឿខុសចេញសោះឡើយ

បើតែយ៉ាងនេះ តើឱ្យក្មេងជំនាន់ក្រោយ ជឿទៅលើព្រះពុទ្ធសាសនា ឱ្យបានស៊ប់យ៉ាងដូចម្ដេចទៅ ។ ពាក្យចាស់ពោលថា ធំពាំងស្នងឫស្សី ស្នងមែនមិនមែនមិនស្នងទេ តែវាជាការស្នងខុស ខុសហើយថែមខុស ប្រកាន់តាមទម្លាប់ប្រពៃណី មិនយកច្បាប់ជាធំ បែរជាយកតែទម្លាប់...ខ្ញុំមិនបានហាមឃាត់មិនឱ្យធ្វើនោះទេ តែសូមឱ្យមានគំនិតគិតផង តើអ្នកធ្វើដើម្បីឱ្យខុសឬមួយធ្វើដើម្បីឱ្យត្រូវ ?

ខ្ញុំយល់ អ្នកដែលធ្វើគ្រប់គ្នាគឺចង់ឱ្យត្រូវ គ្មាននរណាម្នាក់ចង់ឱ្យខុសនោះឡើយ តែវាដំ

ណាលគ្នានឹងចង់ឱ្យត្រូវនោះ ចួនកាលវាកំពុងតែខុសក៏មានដែរ ហើយមានគំនិតគិតថាត្រូវមិនខុសឡើយ ។

ឥឡូវ យើងគួរតែគិតពីរឿងបានលាភនៃយើងគ្រប់គ្នាវិញ ដែលមានចំពោះព្រះរតនត្រៃ មានព្រះពុទ្ធរតនៈជាដើម ។ សូមឱ្យពុទ្ធបរិស័ទដែលជាអ្នកបាន សទ្ធា ចំពោះព្រះត្រៃរ័ត្ន កុំឱ្យមានសេចក្តីប្រែប្រួលដទៃក្រៅពីការជឿលើគុណនៃព្រះរតនៈទាំង ៣ ឡើយ ។

# ៤-សិក្ខានុត្តរិយៈ

( បិដកលេខ ៤៦ ទំព័រ ១០ )

ពាក្យថា សិក្ខានុត្តរិយៈ គឺមានន័យថា ការសិក្សាដ៏ប្រសើរ ។

នៅក្នុងអដ្ឋកថាដ៏ដែលបានសម្តែងថា ៖ ម្នាលភិក្ខុទាំងឡាយ តើសិក្ខានុត្តរិយៈ មានសេចក្តីយ៉ាងណា ?

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រមែងសិក្សាសិល្បៈ ទាក់ទិននឹងដំរីខ្លះ សេះខ្លះ រថខ្លះ ធ្នូរខ្លះ ដាវខ្លះ ឬសិក្សាសិល្បៈថ្នាក់ខ្ពស់ខ្លះ ថ្នាក់ទាបខ្លះ រមែងសិក្សាជាមួយ

សមណព្រាហ្មណ៍អ្នកមានការយល់ខុស អ្នកបដិបត្តិខុស ។

ម្នាលភិក្ខុទាំងឡាយ ការសិក្សានេះមានតថាគតមិនបានពោលថា មិនមានទេ ។

ម្នាលភិក្ខុទាំងឡាយ តែថាការសិក្សានេះជារបស់អាក្រក់ ។ល។ រមែងប្រព្រឹត្តទៅមិនដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាមុតមាំ រមែងសិក្សាអធិសីលខ្លះ អធិចិត្តខ្លះ

អធិបញ្ញាខ្លះ នៅក្នុងធម្មវិន័យដែលតថាគតប្រកាសហើយ ។

ម្នាលភិក្ខុទាំងឡាយ ការសិក្សានេះ ប្រសើរជាងការសិក្សាទាំងឡាយ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។ល។ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ ប្រការដែលអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង រមែងសិក្សាអធិសីលខ្លះ អធិចិត្តខ្លះ អធិបញ្ញាខ្លះ ក្នុងធម្មវិន័យដែលតថាគត

បានប្រកាសហើយ នេះតថាគត ហៅថា សិក្ខានុត្តរិយៈ ។

ពុទ្ធបរិស័ទទាំងឡាយ ដែលជាអ្នកយកចិត្តទុកដាក់ នឹងការសិក្សាព្រះធម៌របស់ព្រះពុទ្ធអម្ចាស់គ្រប់គ្នា យើងត្រូវតែគិតឱ្យបានល្អនៅក្នុងការសិក្សារបស់យើង ។ ការរៀនសូត្រនៃពុទ្ធបរិស័ទ គឺមានកម្រិត តាមថ្នាក់តាមជាន់ មិនមែនចេះតែសិក្សា ដោយគ្មានគោលការណ៍ មិនពិតប្រាកដនោះឡើយ ។

អ្នករៀនកម្មដ្ឋាន ឬ សិក្សានូវវិបស្សនាក្តី សូមកុំគិតថា មិនមានប្រយោជន៍ឱ្យសោះ ការ

សិក្សានៅក្នុងព្រះសាសនា គឺមិនមែនមិនមាន ផលប្រយោជន៍នោះឡើយ គឺមានប្រយោជន៍ ជាអនេកក្រាស់ក្រៃណាស់ ។

ប៉ុន្តែ ចំណេះវិជ្ជានៅក្នុងលោកយើងនេះ គឺ មិនមានទីបំផុតនោះទេ លុះត្រាណាតែបែរ មកសិក្សា នៅក្នុងសំណាក់ព្រះសាសនារបស់ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទើបការសិក្សារបស់ អ្នករកឃើញនៅទីបញ្ចប់បាន ។ ការសិក្សានៅ ក្នុងលោកនេះមានច្រើនណាស់ ដូចជាការរៀន នូវចំណេះដឹងខាងគ្រប់គ្រង ជំនាញខាងភាសា អង់គ្លេសជាដើម ការសិក្សានេះមានមែន តែ

មិនមែនជាការសិក្សា ដើម្បីដល់ទីបញ្ចប់នៃការរៀនសូត្ររបស់យើងគ្រប់គ្នាឡើយ ។

បានត្រឹមតែការដក់នៅជាប់នៅ ក្នុងវាលវដ្តសង្សារនេះតែប៉ុណ្ណោះ ឯរឿងផុតទុក្ខនោះគឺមិនមានឡើយ ។ សូមឱ្យពុទ្ធបរិស័ទគ្រប់គ្នាបានរួចចាកពីសង្សារវដ្តដ៏ធំល្វឹងល្វើយ សូមឱ្យបានដល់ទីក្សេមក្សាន្ត កុំបីអាក់ខានឡើយ សូមអនុមោទនា ។

# ៥-បារិចរិយានុត្តរិយៈ

( បិដកលេខ ៤៦ ទំព័រ ១០ )

ពាក្យថា បារិចរិយានុត្តរិយៈ គឺមានន័យថា ការទំនុកបម្រុងដ៏ប្រសើរ ។

នៅក្នុងព្រះអដ្ឋកថា បដិសម្ភិទាមគ្គបានសម្តែងថា ៖

ម្នាលភិក្ខុទាំងឡាយ តើបារិចរិយានុត្តរិយៈ មានន័យយ៉ាងណា ?

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រមែងទំនុកបម្រុងក្សត្រខ្លះ ព្រាហ្មណ៍ខ្លះ គហបតីខ្លះ ឬ ថារមែងទំនុកបម្រុងបុគ្គលថ្នាក់

ខ្ពស់ ថ្លាក់ទាប ឬ រមែងទំនុកបម្រុងសមណ ព្រាហ្មណ៍ដែលមានការយល់ខុស អ្នកបដិបត្តិ ខុស ។

ម្នាលភិក្ខុទាំងឡាយ ការទំនុកបម្រុង នេះមាន តថាគតមិនបានពោលថា ការទំនុក បម្រុងនេះមិនមានទេ ។

ម្នាលភិក្ខុទាំងឡាយ តែការទំនុកបម្រុង នេះ ជាការទំនុកបម្រុងដ៏អាក្រក់ ។ល។ មិនប្រ ព្រឹត្តទៅដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ តែថា បុគ្គលណា អ្នកមានសទ្ធាតាំងមាំ មានសេចក្ដីស្រឡាញ់

តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង រមែងទំនុកបម្រុងតថាគត ឬ សាវករបស់ព្រះតថាគត ។

ម្នាលភិក្ខុទាំងឡាយ ការទំនុកបម្រុងនេះប្រសើរជាងការទំនុកបម្រុងទាំងឡាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធ ដល់សត្វទាំងឡាយ ។បេ។ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ ប្រការដែលបុគ្គលអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តី

ជ្រះថ្លាមុតមាំ រមែងទំនុកបម្រុងព្រះតថាគ ឬសាវករបស់ព្រះតថាគត នេះតថាគតហៅថា ចារិចរិយានុត្តរិយៈ។

ន័យខាងលើនេះ សូមពុទ្ធបរិស័ទគ្រប់គ្នាកុំយល់ច្រឡំឱ្យសោះថា ព្រះអង្គទ្រង់ហាមឃាត់មិនឱ្យកូនទាំងឡាយ ទៅបម្រើមាតាបិតាគោរពចាស់ព្រឹទ្ធាចារ្យជាដើមឡើយ តែព្រះអង្គមានព្រះទ័យ សម្តែងដល់កិច្ចបដិបត្តិរបស់ពុទ្ធបរិស័ទទាំងឡាយ ឱ្យបែរនឹងកាន់ស៊ប់នៅក្នុងការទំនុកបម្រុង ដល់ព្រះភិក្ខុសង្ឃដែលនឹងទទួលបាននូវផលផ្លែផ្កាយ៉ាងគាប់ចិត្ត

នៅទីបំផុត នៃការគាល់បម្រើទំនុកបម្រុងព្រះត្រៃរ័ត្ន ។ មិនមែនជារឿងធម្មតាឡើយ អានិ - សង្សនៃការបម្រើ ឬ ទំនុកបម្រុងព្រះរតនៈត្រៃនេះនឹងបានដល់នូវព្រះនិព្វានផងដែរ ។

តែគួរអាណិតដល់អ្នកមួយចំនួន ដែលគ្នាកំពុងតែមានអវិជ្ជាបាំងបិទ មិនឱ្យជ្រួតជ្រាបពីគុណបំណាច់នៅក្នុងការទំនុកបម្រុង ទៅលើគុណព្រះរតនៈត្រៃ ។

យ៉ាងហោចណាស់១ជីវិត សូមឱ្យបានទៅទំនុកបម្រុងព្រះសង្ឃឱ្យបាន១ថ្ងៃដែរ ។

# ៦- អនុស្សតានុត្តរិយៈ

( បិដកលេខ ៤៦ ទំព័រ ១០ )

ពាក្យថា អនុស្សតានុត្តរិយៈ គឺមានន័យថា ការរឭកដល់ដ៏ប្រសើរ ។

នៅក្នុងអដ្ឋកថា បដិសម្ភិទាមគ្គសម្ដែងថា ៖ ម្នាលភិក្ខុទាំងឡាយ តើអនុស្សតានុត្តរិយៈ មានន័យយ៉ាងណា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ រមែងរឭកដល់ការបានបុត្រខ្លះ ការបានភរិយាខ្លះ ការបានទ្រព្យខ្លះ ឬថារមែងរឭកដល់ការបានច្រើនខ្លះ តិចខ្លះ ឬរឭកដល់

សមណព្រាហ្មណ៍អ្នកមានការយល់ខុស អ្នកបដិបត្តិខុស ។

ម្នាលភិក្ខុទាំងឡាយ ការរឮកនេះមានតថាគតមិនបានពោលថាមិនមានទេ ។

ម្នាលភិក្ខុទាំងឡាយ តែថាការរឮកនេះជាការរឮកដ៏អាក្រក់ ។ល។ រមែងមិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ តែថា បុគ្គលណាអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាដ៏មុតមាំ រមែងរឮកដល់តថាគត ឬសា-

វករបស់ព្រះតថាគត ។

ម្នាលភិក្ខុទាំងឡាយការរឭកនេះប្រសើរទាំងឡាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ ប្រការដែលបុគ្គលអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាដ៏យ៉ាងក្រៃលែង រមែងរឭកដល់ព្រះតថាគត ឬសាវករបស់ព្រះតថាគត ។

ម្នាលភិក្ខុទាំងឡាយ នេះតថាគតត្រាស់ហៅថា អនុស្សតានុត្តរិយៈ ។

ការនឹករឭកនៅក្នុងលោកនេះ គឺ មិនមានទីបញ្ចប់ឡើយ ជាពិសេសបុថុជ្ជនអ្នកនៅក្នុងអំណាចនៃរាគៈ ទោសៈ មោហៈ គឺតែងតែនឹករឭកដល់អ្វីដែលជារបស់ក្លែងក្លាយ វត្ថុគ្រាន់តែបំភាន់ភ្នែកតែប៉ុណ្ណោះ ។ អ្នកដែលនៅតែម្នាក់ឯងនៅក្នុងទីស្ងាត់ ច្រើនតែនឹករឭកដល់អ្វីដែលបានកន្លងទៅ និងគិតអ្វីដែលមិនទាន់នឹងកើតឡើង និងគិតដល់អ្វីដែលខ្លួនកំពុងតែមានគ្រប់ពេលវេលា រិះរកវិធីសាស្ត្រយ៉ាងណាដើម្បីនឹងកែខៃកែប្រែថែរក្សាឱ្យគង់វង់ ឱ្យវត្ថុនោះតាំងនៅជាដ៏រាប ។ សេចក្ដីនឹករឭកនៃជន

ដែលមិនមានបញ្ហាច្រើនតែបែបនេះឯង ក្រៅពីការនឹករឭកគឺនឹងស្វែងរកមកបន្ថែមទៀត ។

តែសូមកុំយល់ច្រឡំថា ព្រះសម្មាសម្ពុទ្ធទ្រង់ហាមឃាត់មិនឱ្យយើងនឹករឭក ទៅដល់អ្វីដែលយើងមាននោះទេ នៅក្នុងចំណុចនេះ គឺសម្រាប់ពុទ្ធបរិស័ទ ដែលកំពុងតែសិក្សាបដិបត្តិខ្លួន ដើម្បីរើខ្លួននេះឱ្យផុតពីពាក្យថាអត្តានោះឯង ។ ជាការពិតណាស់ពុទ្ធបរិស័ទអ្នកបដិបត្តិទាំងឡាយ មិនមែនប្រព្រឹត្តធម៌ ឬចម្រើនធម៌ ដើម្បីឱ្យស្ថិតនៅ ជាប់នៅក្នុងសង្សារវដ្តនេះឡើយ តែគឺដើម្បីរើខ្លួនឱ្យបាន

រួចចាកផុតទុក្ខពីខន្ធបញ្ចកៈនេះឯង ។

ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ ជាដើមដែលទុកជាកាតព្វកិច្ចសម្រាប់ពុទ្ធបរិស័ -ទត្រូវតែមានវីរិយៈនិងឆន្ទៈ ឱ្យបានគ្រប់គ្រាន់ ដើម្បីផ្ដើមការនឹករឭកនៅក្នុងឥរិយាបថ ៤ ។

នឹកភរិយាស្វាមី នឹកកូននឹកចៅនឹកយាយ នឹកតាជាដើម មិនមែនឥតប្រយោជន៍ឡើយ តែផ្ទុយទៅវិញ គឺវាមានសារៈសំខាន់ជាទីបំផុត ដែលមិនអាចកាត់ថ្លៃបាន ព្រោះបើភរិយាណា កូនណា ម្ដាយណា យាយណា មិនចេះនឹករឭក ដល់គ្នា អ្នកនោះគឺជាមនុស្សអកតញ្ញូដោយពិត

។ តែសូមជ្រាបផងថា ការប្រព្រឹត្តធម៌របស់អ្នកគឺដើម្បីលះបង់ឧបាទាន ចំណុចដែលថាកូនជាដើមត្រូវតែនឹករឮកដល់អ្នកមានគុណ គឺជាការសម្មតិ តែត្រង់ថាដើម្បីលះបង់ឧបាទានគឺជាបរមត្ថធម៌ សម្រាប់បរិស័ទអ្នកបដិបត្តិធម៌នេះឯង ដូច្នេះ ការសន្មតិ ដែលជាសម្មតិសច្ចៈមិនដូចជាបរមត្ថសច្ចៈឡើយ ។

នៅក្នុងឥរិយាបថ ៤ អ្នកដែលប្រព្រឹត្តធម៌ គឺត្រូវតែមាននូវសតិឱ្យបានគ្រប់គ្រាន់ កុំបីធ្វេសប្រហែស និង កុំបណ្តោតបណ្តោយទៅតាមពេលវេលាឱ្យសោះ ហើយត្រូវគិតថា

ពេលវេលាមានតិចណាស់ សម្រាប់អ្នកបដិបត្តិធម៌ទាំងឡាយនៅក្នុងព្រះសាសនានេះ ។

អ្នកប្រមាទឈ្មោះថាស្លាប់ទាំងរស់ តែអ្នកដែលមិនប្រមាទឈ្មោះថាមិនស្លាប់ឡើយ តើអ្នកចង់ស្លាប់ទាំងរស់ ឬ មួយចង់រស់ ? មនុស្សឆ្លាតគេមិនចង់ស្លាប់ទាំងរស់ឡើយ តែគេចង់នៅដើម្បីស្វែងរកទិសដៅមួយដ៏ពិតប្រាកដទុកបានជាទីពឹងសម្រាប់ខ្លួនគេ ។ តើអ្នកយល់យ៉ាងណាដែរ ?

**កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប !**

# សិក្សាតាមព្រះ

( បិដកលេខ ១៨ ទំព័រ ១១៥ )

**១-ភគវា ឯតទវោច អត្តទីបា ភិក្ខវេ វិហរតិ អត្តស្សរណា អនញ្ញស្សរណា ធម្មទីបា ធម្មស្សរណា អនញ្ញស្សរណា ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ កុំមានរបស់ដទៃ ជាទីពឹងពំនាក់ឡើយ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ កុំមាន

របស់វាទៅជាទីពឹងពំនាក់ឡើយ ។

**២-គោចរេ ភិក្ខវេ ចរថ សកេ បេត្តិកេ វិសយេ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រព្រឹត្តក្នុងគោចរ ជាវិស័យដែលមានធម៌អំពីបិតានៃខ្លួន ។

**៣-ន ខោ អហំ ចុន្ទ ទិដ្ឋធម្មិកានំយេវ អាសវានំ សំវរាយ ធម្មំ ទេសេមិ ន បនាហំ ចុន្ទ សម្បរាយិកានំយេវ អាសវានំ បដិឃាតាយ ធម្មំ ទេសមិ ទិដ្ឋធម្មិកានំ ចេវាហំ ចុន្ទ អាសវានំ សំវរាយ ធម្មំ ទេសមិ សម្បរាយិកានំ**

# ច អាសវានំ បដិឃាតាយ ។

ម្នាលចុន្ទ តថាគតមិនសម្តែងធម៌ ដើម្បីរារាំងនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន តែមួយយ៉ាងដល់ពួកអ្នកទេ

ម្នាលចុន្ទ តថាគតមិនសម្តែងធម៌ ដើម្បីកម្ចាត់បង់ នូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខប៉ុណ្ណោះទេ

ម្នាលចុន្ទ តថាគតសម្តែងធម៌ ដើម្បីរារាំងនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង ដើម្បីកម្ចាត់បង់នូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខ

ផង។

# ៤-គ្រឿងចងរួបរឹតសត្វទុក

( បិដេកលេខ ១៧ ទំព័រ ២១៤)

ពួកទេវតា មនុស្ស អសុរ នាគ និងគន្ធព្វ ទាំងពួកជនច្រើនដទៃៗមានឥស្សានិងមច្ឆរិយៈ ជាគ្រឿងចងរួបរឹតទុក បានជាពួកសត្វទាំងនោះ សូម្បីប្រាថ្នាថា សូមឱ្យយើងទាំងឡាយ ជាអ្នកមិនមានពៀរ មិនមានអាជ្ញា មិនមានសត្រូវ មិនមានព្យាបាទ នៅដោយមិនមានពៀរនឹងគ្នា ពួកសត្វទាំងនោះ តែងមានសេចក្តីប្រាថ្នាដូច្នេះឯង ទោះបីមានសេចក្តីប្រាថ្នា

ដូច្នោះ ក៏គង់សត្វទាំងនោះ នៅតែជាអ្នកមាន ពៀរ មានអាជ្ញា មានសត្រូវ មានព្យាបាទ នៅ ដោយមានពៀរនឹងគ្នាដ៏ដែល ។

## ៥-ហេតុដែលធ្វើឱ្យកើតនូវឥស្សា និងមច្ឆរិយៈ

( បិដកលេខ ១៧ ទំព័រ ២១៦ )

ឥស្សានិងមច្ឆរិយៈ មានសេចក្តីស្រឡាញ់និងសេចក្តីស្អប់ជាដើមហេតុ សេចក្តីស្រឡាញ់និងសេចក្តីស្អប់នាំឱ្យកើត... ។

## ៦-ហេតុឱ្យកើតនូវសេចក្តីស្រឡាញ់ និងសេចក្តីស្អប់

( បិដកលេខ ១៧ ទំព័រ ២១៦ )

សេចក្តីស្រឡាញ់ និង សេចក្តីស្អប់ មាន**ឆន្ទៈ**ជាដើមហេតុនាំឱ្យកើត ។

## ៧-ហេតុឱ្យកើតនូវធម៌ឆន្ទៈ

( បិដកលេខ ១៧ ទំព័រ ២១៧ )

ឆន្ទៈ មាននូវវិតិក្កៈជាដើមហេតុ នាំឱ្យកើត ។

## ៨-គួរសមាទានដោយសេចក្តីមិនប្រមាទក្នុងសិក្ខាបទទាំងឡាយ

( បិដកលេខ ២០ ទំព័រ ១០៦ )

**ភគវា ឯតទវោច សម្បន្នសីលា ភិក្ខវេ វិហរថ សម្បន្នបាតិមោក្ខា បាតិមោក្ខសំវរសំវុតា វិហរថ អាចារ**

**-សម្បន្នានណអឈោមត្តេសុ វជ្ជេសុ ភយ-ទស្សាវិនោ សមាទាយ សិក្ខថ សិក្ខា-បទេសុ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាអ្នកមានសីលបរិបូណ៌ មានបាតិមោក្ខបរិបូណ៌ សង្រួមក្នុងបាតិមោក្ខសំវរៈ ចូរជាអ្នកមានអាចារៈនឹងគោចរៈដ៏បរិបូណ៌ ឃើញភ័យក្នុងទោសត្រឹមតែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។

## ៩-ទុគ្គតិឬឋានសួគ៌គឺមកពីចិត្ត

( បិដកលេខ ២០ ទំព័រ ១១៥ )

ម្នាលភិក្ខុទាំងឡាយ កាលបើចិត្តសៅ

ហ្មងហើយ ទុគ្គតិនឹងមានប្រាកដ ។

# ១០-ភិក្ខុអ្នកមានធម៌២យ៉ាងរមែងនៅដោយសេចក្ដីចង្អៀតចង្អល់

( បិដកលេខ ៥៣ ទំព័រ ៣១ )

ភិក្ខុណា ក្នុងសាសនានេះ មិនបានគ្រប់គ្រងទ្វារអម្បាលនេះគឺ ៖

១-ចក្ខុ

២-សោតៈ

៣-ឃានៈ

៤-ជិវ្ហា

៥-កាយៈ

៦-មនៈ ជាអ្នកមិនដឹងប្រមាណក្នុងភោជន មិន

សង្រួមក្នុងឥន្ទ្រិយ៍ទាំងឡាយ ភិក្ខុនោះតែង បាននូវសេចក្តីទុក្ខ គឺ ទុក្ខក្នុងកាយផង ទុក្ខក្នុង ចិត្តផង ភិក្ខុបែបនេះមានកាយក្តៅក្រហាយ មានចិត្តក្តៅក្រហាយ តែងនៅជាទុក្ខទាំងថ្ងៃ ទាំងយប់ ។ ធម៌ទាំងពីរយ៉ាងនោះគឺ ៖

១-មិនសង្រួមឥន្ទ្រិយ៍

២-មិនស្គាល់ប្រមាណក្នុងភោជន ។

## ១១-ចង់អស់នូវសំយោជនៈ ត្រូវតែស្គាល់នូវកល្យាណមិត្ត

( បិដកលេខ ៥៣ ទំព័រ ១៥ )

ភិក្ខុណាមានកល្យាណមិត្ត មានសេចក្តី កោតក្រែង ប្រកបដោយសេចក្តីគោរព ធ្វើ

តាមពាក្យរបស់កល្យាណមិត្ត ជាអ្នកមានសេចក្តីដឹងខ្លួន មានស្មារតី ភិក្ខុនោះទើបគួរដល់នូវកិរិយាអស់ទៅសំយោជនៈទាំងពួង ដោយលំដាប់បាន ។

## ១២-បុគ្គលអ្នកបំបែកសង្ឃ នឹងឆេះនៅក្នុងនរកអស់ ១ កប្ប

( បិដកលេខ ៥៣ ទំព័រ ១៦ )

បុគ្គលជាអ្នកបំបែកសង្ឃ ត្រេកអរក្នុងពួក មិនស្ថិតក្នុងធម៌ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំងនៅអស់មួយកប្ប រមែងសាបសូន្យចាកធម៌ ជាទីក្សេមចាកយោគៈ បុគ្គលបំបែកសង្ឃ ដែលព្រមព្រៀងគ្នាហើយ

តែងឆេះនៅក្នុងនរកអស់ ១ កប្ប ។

## ១៣-បព្វជិតពិតជាបានសុខដ៏ឧត្តម ពេលដែលបានសាមគ្គីគ្នា

( បិដកលេខ ៥៣ ទំព័រ ១៧ )

សេចក្តីព្រមព្រៀងនៃសង្ឃ ជាហេតុនាំសេចក្តីសុខមកឱ្យ ការអនុគ្រោះបុគ្គលទាំងឡាយ ដែលមានសេចក្តីព្រមព្រៀងគ្នា ( ជាហេតុនាំសេចក្តីសុខមកឱ្យ ) បុគ្គលត្រេកក្នុងជនដែលព្រមព្រៀងគ្នា តាំងនៅក្នុងធម៌ រមែងមិនសាបសូន្យចាកយោគៈ បុគ្គលធ្វើសង្ឃឱ្យព្រមព្រៀងគ្នា រមែងរីករាយក្នុងឋានសួគ៌អស់ ១ កប្ប ។

# ១៤-បុណ្យតែងនាំសុខមកឱ្យយើង ដូច្នេះយើងចូរកុំខ្លាចបុណ្យ

( បិដកលេខ ៥៣ ទំព័រ ២១ )

**មា ភិក្ខវេ បុញ្ញានំ ភាយិត្ថ សុខ-ស្សេតំ ភិក្ខវេ អធិវចនំ ឥដ្ឋស្ស កន្ត-ស្ស បិយស្ស មនាបស្ស យទិទំ បុញ្ញានិ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំខ្លាចបុណ្យឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុណ្យនេះជាឈ្មោះនៃសេចក្តីសុខដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីស្រឡាញ់ ជាទីពេញចិត្ត ។

# ១៥-បណ្ឌិតទាំងឡាយ តែងសរសើរ នូវសេចក្តីមិនប្រមាទ

( បិដកលេខ ៥៣ ទំព័រ ២១ )

**អប្បមាទំ បសំសន្តិ បុញ្ញកិរិយាសុ បណ្ឌិតោ អប្បមត្តោ ឧភោ អត្ថេ អធិគ-ណ្ហាតិ បណ្ឌិតោ ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ អត្ថា-ភិសមយោ ធីរោ បណ្ឌិតោតិ បវុច្ចតីតិ**

បណ្ឌិតទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទក្នុងបុញ្ញកិរិយាវត្ថុទាំងឡាយបណ្ឌិតមិនប្រមាទហើយ រមែងបានប្រយោជន៍ទាំងពីរ ១ ប្រយោជន៍បច្ចុប្បន្ន ២ ប្រយោជន៍បរ-

លោក អ្នកមានប្រាជ្ញា ព្រោះបានប្រយោជន៍ទាំងពីរ ទើបហៅថាជាបណ្ឌិត ។

## ១៦-បាបមិនដែលមិនកើតឡើងដល់បុគ្គលដែលជាអ្នកកុហកឡើយ ។

( បិដកលេខ ៥៣ ទំព័រ ២៥ )

សត្វដែលកន្លងធម៌ ១ គឺអ្នកពោលពាក្យកុហក មានបរលោកកន្លងបង់ហើយ មិនគប្បីធ្វើអំពើបាបមិនមានឡើយ ។

## ១៧-អ្នកសាងធម៌លាមកតែងទៅកាន់នរក

( បិដកលេខ ៥៣ ទំព័រ ៣៥ )

**បាបកេន ចសីលេន បាបិកាយ ច**

**ទិដ្ឋិយា ឯតេហិ ទ្វីហិ ធម្មេហិ យោ សមន្នាគតោ នរោ កាយស្ស ភេទាទុ-ប្បញ្ញោ និរយំ សោ ឧបបជ្ជតីតិ ។**

ជនណាប្រកបដោយធម៌ ២ យ៉ាងនេះ គឺ ដោយសីលលាមក ដោយទិដ្ឋិលាមក ជនអ្នកឥតបញ្ញានោះ លុះបែកធ្លាយរាងកាយទៅ តែងចូលទៅកាន់នរក ។

## ១៨-សត្វដែលខិតផ្លូវចិត្ត ក្នុងលោកគឺមានតែធម៌ឯកតែ មួយគត់គឺមោហៈ

( បិដកលេខ ៥៣ ទំព័រ ១២ )

ពួកសត្វត្រូវមោហៈដែលជាធម៌ឯក មិន

មានធម៌ដទៃដូច រួបរឹតបិទបាំងយ៉ាងនេះហើ-
យ តែងអន្ទោលទៅអស់ថ្ងៃនិងយប់ដ៏វែង ចំ
ណែកសត្វទាំងឡាយណា លះបង់មោហៈ ទំ-
លាយគំនរងងឹតហើយ សត្វទាំងឡាយ
នោះនឹងមិនអន្ទោលទៅទៀត ព្រោះហេតុ
របស់សត្វទាំងនោះមិនមាន ។

## ១៩-ត្រូវតែផ្តួចចិត្ត ទើបអស់ទុក្ខបាន

( បិដកលេខ ៥៣ ទំព័រ ៣៥ )

យោនិសោមនសិការៈ ជាធម៌របស់ភិក្ខុ
ជាសេក្ខៈ ធម៌ដទៃ ដែលមានឧបការៈច្រើន
ដើម្បីសម្រេចប្រយោជន៍ ដ៏ឧត្តមដូច្នោះមិន

មានឡើយ កាលភិក្ខុផ្គងចិត្ត ដោយឧបាយ ទើបដល់នូវការអស់ទុក្ខបាន ។

## ២០-បើមិនមានបញ្ញាហើយ ទុគ្គតិរង់ចាំ

( បិដកលេខ ៥៣ ទំព័រ ៩៥ )

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា សូន្យចាកបញ្ញាដ៏ប្រសើរហើយ សត្វទាំងឡា-យនោះ ឈ្មោះថាសាបសូន្យអស់រលីង សត្វទាំងឡាយនោះរមែងនៅជាទុក្ខ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ

ប្រាកដជាទៅកាន់ទុគ្គតិ ។

## ២១-មនុស្សខ្វាក់ តែងតោងចាប់ខុស

( បិដកលេខ ៥៣ ទំព័រ ៤៧ )

អ្នកចូរមើលនូវសត្វលោក ព្រមទាំងទេវ-លោក ដែលជាប់នៅក្នុងនាមនិងរូប រមែងសម្គាល់ថា នេះជារបស់ពិត ព្រោះសាបសូន្យចាកបញ្ញាដ៏ប្រសើរ ។

## ២២-បើអ្នកមិនមានធម៌ហិរិ និង ឱត្តប្បៈទេ អ្នកនឹងមិនរួចពីជាតិនិង ជរាឡើយ

( បិដកលេខ ៥៣ ទំព័រ ៤៨ )

បើហិរិនឹងឱត្តប្បៈ មិនមានដល់សត្វទាំងឡាយណាសព្វកាលទេ សត្វទាំងឡាយនោះ ជាអ្នកឃ្លាតចាកឫសគល់នៃធម៌ស មានដំណើរទៅកាន់ជាតិនឹងមរណៈ ។

## ២៣-កុំត្រេកអរនឹងកាយ តែគួរសម្លឹងឆ្ពោះព្រះនិព្វាន

( បិដកលេខ ៥៣ ទំព័រ ៤៩ )

បុគ្គល មិនគួរត្រេកអរនឹងកាយនោះ ដែលកើត ដែលមាន ដែលកើតព្រម ដែលបានធ្វើ ដែលបច្ច័យតាក់តែងហើយ ជារបស់មិនទៀង ជារបស់ដែលជរានិងមរណៈតាក់តែងហើយ ជាទីនៅនៃរោគ ជារបស់ពុកផុយ

រលួយ មានអាហារនិងតណ្ហាជាប្រភព(ជាដែនកើត) ឯព្រះនិព្វានជាគ្រឿងរលាស់ចេញនូវកាយនោះ ទើបជារបស់ស្ងប់មិនជារបស់ប្រព្រឹត្តទៅតាមសេចក្តីត្រិះរិះ ជារបស់ទៀង ជារបស់មិនកើត មិនកើតព្រម មិនមានសោកប្រាសចាកសេចក្តីត្រេកអរ ការរលត់នូវហេតុនៃទុក្ខទាំងឡាយ ការរម្ងាប់នូវសង្ខារ ជាគុណនាំមកនូវសេចក្តីសុខ ។

## ២៤-បញ្ញាកំណត់ដឹង ពិតជាប្រាជ្ញាបន្ទាបមច្ចុបាន

( បិដកលេខ ៥៣ ទំព័រ ៦០ )

ជនទាំងឡាយណា កំណត់ដឹងក្នុងរូបធាតុ

មិនតាំងនៅក្នុងអរូបធាតុ ចុះចិត្តស៊ប់ក្នុងនិរោធ ជនទាំងនោះឈ្មោះថា ញ៉ាំងមច្ចុឱ្យសាបសូន្យ ។

អត្ថន័យខាងលើនេះ គឺខ្ញុំមិនបានពន្យល់ ឬពង្រីកសេចក្ដីនោះទេ គឺសម្រាប់ពុទ្ធបរិស័ទទាំងឡាយរៀនត្រិះរិះដោយខ្លួនឯង ដើម្បីបាននូវបញ្ញាថ្នាក់ចិន្តាមយបញ្ញា ។

សេចក្ដីខាងលើនេះ គឺ ជាព្រះពុទ្ធដីកាទាំងស្រុងដែលខ្ញុំដកស្រង់មក ដើម្បីបានជាទីជំនួយស្មារតីដល់ពុទ្ធបរិស័ទ ដែលជាអ្នកបានបដិបត្តិធម៌ ដើម្បីឈានទៅដល់ការដុតកម្លោច

នូវបាបធម៌ក្នុងចិត្ត សូមអនុមោទនាបុណ្យ ។

សូមឱ្យអ្នកអានទាំងឡាយ បានទទួលនូវចំណេះដឹងដ៏ពិតប្រាកដ នៅក្នុងព្រះពុទ្ធសា - សនាជាអម្ចាស់ សូមឱ្យសព្វសត្វទាំងឡាយ បានរួចចាកទុក្ខ បានផុតពីសង្សារវដ្តកុំបីក្លាយទៅជាប្រការៈដទៃទៀយ សូមអនុមោទនា ។

មយ៉ាងទៀត ដោយអំណាចបុណ្យធម្មទានខ្ញុំឧទ្ទិសនូវចំណែកបុណ្យនេះ ដល់ពពួកនៅក្នុងសង្សារវដ្ត ពពួកទេវតាទាំងអស់ ស្តេចយមរាជ សក្កទេវរាជ សូមឱ្យបានបុណ្យ និង រួចចាកទុក្ខគ្រប់ៗគ្នា សូមអនុមោទនា ។

ខ្ញុំសូមអភ័យទោសផងដែរ រាល់ពាក្យដែលបានសរសេរទៅ ហើយមានខុសដោយក្ដីអចេតនា សូមប្រណីអភ័យមេត្តាដោយក្ដីអនុគ្រោះដល់ខ្ញុំផង ។



# អ្នកដឹង អ្នកឃើញ

**ជានតោ អហំ ភិក្ខវេ បស្សតោ អាសវានំ**
**ខយំ វទាមិ នោ អជានតោ អបស្សតោ ។**

*ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅ*
*នៃសអាសវៈទាំងឡាយ ចំពោះបុគ្គលដែលដឹង ដែលឃើញ*
*មិនមែនចំពោះបុគ្គលដែលមិនដឹង មិនឃើញទេ ។*

(បិដកលេខ៣៩ ទំព័រ ២៦៧)

ថ្ងៃសុក្រ ១៥កើត ខែវិសាខ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៥៥៧
ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៣